# សំណួរចម្លើយអំពីកម្មវិធី Starbucks Rewards™

## ជំពូក១: សំណួរចម្លើយអំពីកាត Starbucks

១. តើកាត Starbucks ជាអ្វី?

កាត Starbucks សំដៅដល់កាតប្លាស្ទិកដែលមានរូបរាង និងមានបិទម៉ាក Starbucks ដែលអតិថិជនអាចបញ្ចូល ឬ បន្ថែមលុយក្នុងកាតនោះ សម្រាប់ប្រើប្រាស់ដើម្បីធ្វើការជាវក្នុងហាង Starbucks ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

២. តើខ្ញុំអាចស្វែងរកកាត Starbucks នៅទីណា?

កាត Starbucks មានលក់នៅតាមគ្រប់បណ្តាហាង Starbucks ទាំងអស់ ដែលមាននៅក្នុងប្រទេសកម្ពុជា ។

៣. តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីឲ្យកាត Starbucks អាចដាក់ដំណើរការបាន?

កាត Starbucks អាចដាក់ដំណើរការបាន តាមរយៈការបញ្ចូលទឹកប្រាក់ យ៉ាងតិច ប្រាំ (៥) ដុល្លារអាមេរិក ចូលទៅក្នុងកាត Starbucks នីមួយៗ សម្រាប់ការប្រើប្រាស់លើកដំបូង ។

៤. តើកាត Starbucks អាចប្រើប្រាស់បាននៅទីណាខ្លះ?

កាត Starbucks អាចប្រើប្រាស់បានតែនៅតាមបណ្តាហាង Starbucks ដែលមាននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។

៥. តើខ្ញុំអាចប្រើប្រាស់កាត Starbucks ដែលបានបង្កើតនៅក្នុងប្រទេសកម្ពុជា នៅឯក្រៅប្រទេសបានឬទេ?

កាត Starbucks ដែលបានបង្កើតនៅក្នុងប្រទេសកម្ពុជា មិនអាចប្រើប្រាស់បាននៅក្រៅប្រទេសនោះទេ ។ កាត Starbucks អាចប្រើប្រាស់បានតែ នៅតាមបណ្តាហាង Starbucks ដែលមាននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។

៦. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីចុះបញ្ជីកាត Starbucks នៅក្នុងប្រព័ន្ធ?

វាជាការងាយស្រួលបំផុត ដោយលោកអ្នកគ្រាន់តែចំណាយពេលពីរ ទៅបី នាទីប៉ុណ្ណោះ ដើម្បីធ្វើការចុះបញ្ជីកាត Starbucks របស់លោកអ្នកទៅក្នុងប្រព័ន្ធ តាមរយៈការចូលទៅក្នុងកម្មវិធីទូរស័ព្ទ Starbucks® Cambodia ឬគេហទំព័រ https://card.starbucks.com.kh ។ ក្រៅពីការតម្រូវឱ្យផ្តល់ព័ត៌មានផ្ទាល់ខ្លួន លោកអ្នកត្រូវបញ្ចូលលេខកាត 16ខ្ទង់ និងលេខកូដសុវត្ថិភាព 8 ខ្ទង់ ដែលលោកអ្នកអាចស្វែងរកបានតាមរយៈការកោស នៅផ្នែកខាងក្រោយនៃកាតរបស់លោកអ្នក ។

៧.ហេតុអ្វីខ្ញុំត្រូវចុះបញ្ជី កាត Starbucks របស់ខ្ញុំនៅក្នុងប្រព័ន្ធ តាមរយៈការចូលទៅក្នុងកម្មវិធីទូរស័ព្ទ Starbucks® Cambodia ឬគេហទំព័រ https://card.starbucks.com.kh?

ការចុះបញ្ជីកាត Starbucks របស់លោកអ្នកនៅក្នុងប្រព័ន្ធ តាមរយៈការចូលទៅក្នុងកម្មវិធីទូរស័ព្ទ Starbucks® Cambodia ឬគេហទំព័រ https://card.starbucks.com.kh គឺដើម្បីចុះឈ្មោះរបស់លោកអ្នកក្នុងការចូលរួម កម្មវិធី Starbucks Rewards™ នៅទូទាំងប្រទេសកម្ពុជា ។ តាមរយៈកាត ដែលបានចុះបញ្ជីរួចហើយនៅក្នុងប្រព័ន្ធ លោក

អ្នកអាចគ្រប់គ្រងកាត និងសមតុល្យទឹកប្រាក់ក្នុងកាតបានតាមគ្រប់មធ្យោបាយ online ទាំងអស់ ។ លោកអ្នកក៏អាចការពារសមតុល្យសាច់ប្រាក់នៅក្នុងកាត Starbucks របស់លោកអ្នក ក្នុងករណីដែលកាតរបស់លោកអ្នក ត្រូវបានបាត់បង់ ខូចខាត ឬចោរលួច ។

៨. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីបញ្ចូលទឹកប្រាក់ក្នុងកាត Starbucks?
លោកអ្នកអាចបញ្ចូលទឹកប្រាក់ទៅក្នុងកាត Starbucks បានដោយប្រើសាច់ប្រាក់ ឬប័ណ្ណឥណទាន/ឥណពន្ធ នៅតាមបណ្តាហាង Starbucks ទាំងអស់ក្នុងប្រទេសកម្ពុជា ។

៩. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីរាយការណ៍ពេលកាត Starbucks ត្រូវបាត់ឬចោរលួច?
ប្រសិនបើកាត Starbucks របស់លោកអ្នកត្រូវបានបាត់ ខូចខាត ឬចោរលួច លោកអ្នកអាចបាត់បង់ទឹកប្រាក់ដែលមានក្នុងកាត Starbucks ប៉ុន្តែចំនួនផ្កាយមិនបាត់ទេ ប្រសិនបើកាតនោះបានចុះបញ្ជីក្នុងប្រព័ន្ធរួចហើយ ។ សូមធ្វើការហៅមកកាន់ផ្នែកបម្រើសេវាអតិថិជនតាមរយៈលេខទូរស័ព្ទ ០២៣ ៩៨៦ ៥៩១ ឬចូលទៅក្នុងគណនីរបស់លោកអ្នកតាមរយៈគេហទំព័រ https://card.starbucks.com.kh ឬកម្មវិធីទូរស័ព្ទ ដើម្បីធ្វើការជូនដំណឹងពីការបាត់បង់ការខូចខាត ឬចោរលួចកាត Starbucks របស់លោកអ្នក ។ ម៉ោងធ្វើការរបស់ក្រុមការងារយើងខ្ញុំ គឺចាប់ពីម៉ោង ៨:៣០ ព្រឹក ដល់ម៉ោង ៥:០០ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងសម្រាប់ថ្ងៃបុណ្យ ។

១០. តើការបញ្ចូលទឹកប្រាក់មានកំណត់ចំនួនឬទេ?
កាត Starbucks អាចបញ្ចូលទឹកប្រាក់ជាដុល្លារអាមេរិក ក្នុងចំនួនទឹកប្រាក់ ចាប់ពី ពីរ (២.៥០) ដុល្លារអាមេរិកកន្លះ ដល់ ប្រាំរយ (៥០០) ដុល្លារអាមេរិក ដែលទឹកប្រាក់ចំនួន ប្រាំរយ (៥០០) ដុល្លារអាមេរិកនេះ គឺជាចំនួនអតិបរិមាដែលអាចផ្ទុកនៅក្នុងកាតនីមួយៗ ។

១១. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីពិនិត្យសមតុល្យសាច់ប្រាក់ក្នុងកាត Starbucks?
លោកអ្នកអាចពិនិត្យសមតុល្យសាច់ប្រាក់ក្នុងកាត Starbucks តាមរយៈ https://card.starbucks.com.kh ឬ កម្មវិធីទូរស័ព្ទ Starbucks® Cambodia ឬសាកសួរបុគ្គលិក ដែលធ្វើការនៅតាមបណ្តាហាង Starbucks ។

១២. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីទូទាត់សាច់ប្រាក់តាម កាត Starbucks?
លោកអ្នកគ្រាន់តែបង្ហាញកាត Starbucks ឬបារកូដក្នុងកម្មវិធីទូរស័ព្ទ Starbucks® Cambodia ទៅកាន់បុគ្គលិកនៅតាមហាង Starbucks ដើម្បីធ្វើការទូទាត់ទឹកប្រាក់ ។

១៣. តើខ្ញុំអាចប្តូរសមតុល្យសាច់ប្រាក់ដែលមានក្នុងកាត Starbucks ជាសាច់ប្រាក់បានឬទេ?
បន្ទាប់ពីបញ្ចូលទឹកប្រាក់ទៅក្នុងកាត លោកអ្នកមិនអាចប្តូរជាសាច់ប្រាក់វិញបានឡើយ ។

១៤. តើកាត Starbucks មានកាលបរិច្ឆេទផុតសុពលភាពឬទេ?
កាត Starbucks នឹងអស់សុពលភាព ក្នុងរយៈពេល បី (៣) ឆ្នាំ ក្រោយពេលធ្វើប្រតិបត្តិការហិរញ្ញវត្ថុលើកចុងក្រោយ ។ "ប្រតិបត្តិការហិរញ្ញវត្ថុ" គឺជាប្រតិបត្តិការមួយ ក្នុងចំណោមប្រតិបត្តិការខាងក្រោម៖

- ការបញ្ចូលទឹកប្រាក់លើកដំបូង
- ការបញ្ចូលទឹកប្រាក់

- ការប្ដូរយករង្វាន់ដោយប្រើកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួចហើយ
- ប្រតិបត្តិការជាវ
- ការផ្ទេរទឹកប្រាក់រវាងកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួចហើយ (ដូចបានបញ្ជាក់ខាងក្រោម)

បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាព កាត Starbucks នឹងត្រូវបានលុបចោលភ្លាមៗ និងប្រែក្លាយទៅជាកាត ដែលគ្មានសុពលភាព ។

១៥. ប្រសិនបើខ្ញុំបញ្ចូលទឹកប្រាក់ក្នុងកាតនៅក្រៅប្រទេសកម្ពុជា តើខ្ញុំអាចប្រើទឹកប្រាក់នោះ ដើម្បីទិញ និងប្ដូររង្វាន់នៅក្នុងប្រទេសកម្ពុជាឬទេ?
កាត Starbucks អាចប្រើសម្រាប់ការជាវ និងបញ្ចូលទឹកប្រាក់បានតែនៅតាមបណ្ដាហាង Starbucks នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។ សូមបញ្ជាក់ថា ការសន្សំផ្កាយឬប្ដូររង្វាន់ អនុវត្តបានតែនៅតាមបណ្ដាហាង Starbucks ទាំងអស់ ដែលមាននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។

## ជំពូក២: សំណួរពាក់ព័ន្ធនឹងកម្មវិធី Starbucks Rewards™

១. ខ្ញុំត្រូវធ្វើដូចម្ដេច ដើម្បីចូលរួមកម្មវិធី Starbucks Rewards™ ជាមួយកាត Starbucks របស់ខ្ញុំ?
លោកអ្នកអាចចុះឈ្មោះចូលរួមកម្មវិធី Starbucks Rewards™ ហើយចាប់ផ្ដើមសន្សំផ្កាយតាមរយៈការចូលទៅក្នុងគេហទំព័រ https://card.starbucks.com.kh ឬបញ្ចូលកម្មវិធីទូរស័ព្ទ Starbucks® Cambodia រួចអនុវត្តតាមការណែនាំស្ដីពីការបង្កើតគណនី Starbucks Rewards™ និងធ្វើការចុះបញ្ជីកាត Starbucks យ៉ាងតិចចំនួនមួយ (១) ទៅក្នុងគណនីនោះជាការស្រេច ។ បន្ទាប់ពីបង្កើតគណនីរួច លោកអ្នកនឹងទទួលបានអ៊ីម៉ែលសម្រាប់ធ្វើការបញ្ជាក់ឲ្យគណនីដំណើរការ ផ្ញើទៅកាន់អាសយដ្ឋានអ៊ីម៉ែលរបស់លោកអ្នកដែលបានប្រើពេលចុះឈ្មោះ ។

២. តើខ្ញុំអាចមានគណនី Starbucks Rewards™ ចំនួនប៉ុន្មាន?
លោកអ្នកអាចមានគណនី Starbucks Rewards™ ត្រឹមតែមួយ (១) ប៉ុណ្ណោះ ។ ប្រសិនបើលោកអ្នកមានគណនី Starbucks Rewards™ លើសពីមួយ (១) Starbucks តាមរយៈឆន្ទានុសិទ្ធិរបស់ខ្លួន មានសិទ្ធិកំណត់ថាលោកអ្នកបានបំពានលើលក្ខខណ្ឌនៃការប្រើប្រាស់នេះ ។ តាមរយៈឆន្ទានុសិទ្ធិរបស់ខ្លួន Starbucks មានសិទ្ធិក្នុងការផ្អាក លុបចោល ឬរួមបញ្ចូលគណនីណាដែលស្ទួនគ្នា ។ ក្នុងករណីដែលការចូលរួមក្នុងកម្មវិធី Starbucks Rewards™ របស់លោកអ្នកត្រូវបានបញ្ចប់ រាល់ចំនួនផ្កាយនៅក្នុងគណនីរបស់លោកអ្នកក៏ត្រូវបាត់បង់ផងដែរ ។

៣. តើខ្ញុំអាចភ្ជាប់កាត Starbucks ចំនួនប៉ុន្មានទៅក្នុងគណនី Starbucks Rewards™ របស់ខ្ញុំ?
លោកអ្នកអាចភ្ជាប់កាត Starbucks របស់លោកអ្នកក្នុងចំនួនច្រើនបំផុត ចំនួនម្ភៃ (២០) ទៅក្នុងគណនី Starbucks Rewards™ របស់លោកអ្នក ។

៤. តើខ្ញុំអាចផ្ទេរសមតុល្យទឹកប្រាក់ពីកាត Starbucks មួយ ទៅកាន់កាត Starbucks មួយផ្សេងទៀតរបស់ខ្ញុំបាន ឬទេ ប្រសិនបើកាត Starbucks ទាំងនោះបានចុះឈ្មោះរួចហើយ?
សមតុល្យទឹកប្រាក់ក្នុងកាត Starbucks មួយអាចត្រូវបានផ្ទេរទាំងស្រុងពីកាត Starbucks មួយ ទៅកាត Starbucks មួយទៀតបាន តាមរយៈគណនីតែមួយ ប៉ុន្តែការផ្ទេរសមតុល្យដោយផ្នែកមិនត្រូវបានអនុញ្ញាតទេ ។ កាតដែលត្រូវបានផ្ទេរនោះ នឹងប្រែក្លាយទៅជាកាតទទេ ប៉ុន្តែនៅតែបន្តមានសុពលភាពសម្រាប់ការប្រើប្រាស់ និងបញ្ចូលប្រាក់បន្តទៀតបាន ។ ការផ្ទេរសមតុល្យក្នុងកាត Starbucks អាចធ្វើបានដោយខ្លួនរបស់លោកអ្នកផ្ទាល់ តាមរយៈការចូលទៅកាន់គេហទំព័រ ឬកម្មវិធីទូរស័ព្ទ Starbucks® Cambodia ។

៥. តើកម្មវិធី Starbucks Rewards™ ដំណើរការដូចម្តេច?

មានតែប្រតិបត្តិការដែលបានទូទាត់តាមរយៈកាត Starbucks តែប៉ុណ្ណោះ ដែលអាចទទួលបានផ្កាយសម្រាប់បញ្ចូលទៅក្នុងគណនី Starbucks Rewards™ បាន ។
អត្ថប្រយោជន៍ដែលលោកអ្នកអាចទទួលបានពីកម្មវិធី Starbucks Rewards™ គឺអាស្រ័យទៅលើចំនួនផ្កាយដែលលោកអ្នកសន្សំបាន ។ លោកអ្នកអាចសន្សំចំនួនផ្កាយនេះ តាមរយៈការជាវពីក្នុងហាង Starbucks ណាមួយនៅក្នុងប្រទេសកម្ពុជា ដោយលោកអ្នកត្រូវបង្ហាញកាត Starbucks របស់លោកអ្នក ដែលបានចុះបញ្ជីនៅក្នុងប្រព័ន្ធរួចហើយ ឬបារកូដនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks® Cambodia ទៅកាន់បុគ្គលិករបស់ Starbucks នៅពេលទូទាត់ប្រាក់ ។ លោកអ្នកនឹងទទួលបានចំនួនផ្កាយ អាស្រ័យទៅតាមតម្លៃនៃការជាវរបស់លោកអ្នក ដោយលោកអ្នកនឹងទទួលបានផ្កាយចំនួន ១ (មួយ) សម្រាប់ការចំណាយអស់ទឹកប្រាក់ចំនួន ៥០ សេន ដុល្លារអាមេរិក តាមរយៈកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួច ។
បច្ចុប្បន្នអត្ថប្រយោជន៍នៃកម្មវិធី Starbucks Rewards™ មានចំនួន ពីរ (២) កម្រិត ដែលត្រូវបានកំណត់តាមរយៈចំនួនផ្កាយ ដែលបានសន្សំនៅក្នុងគណនីរបស់លោកអ្នក សម្រាប់រាល់រយៈពេល ១២ (ដប់ពីរ) ខែ ជាប់ៗគ្នា ។

**សមាជិកបៃតង៖** ដោយគ្រាន់តែចុះបញ្ជីកាត Starbucks ដែលបានដំណើរការរួចទៅក្នុងប្រព័ន្ធ លោកអ្នកនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិនៅក្នុងកម្រិតអត្ថប្រយោជន៍សមាជិកបៃតង (Green Level) នៃកម្មវិធី Starbucks Rewards™ ដែលមានន័យថាលោកអ្នកនឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- រង្វាន់ខួបកំណើតចំនួនមួយ (១) ដែលនឹងត្រូវផ្តល់ឱ្យនូវភេសជ្ជៈទំហំ Tall មួយកែវ សម្រាប់ខែនៃថ្ងៃខែកំណើតរបស់លោកអ្នក (ការផ្តល់ជូនភេសជ្ជៈដោយឥតគិតថ្លៃនេះ មានសុពលភាពសម្រាប់តែក្នុងខែខួបកំណើតរបស់លោកអ្នកតែប៉ុណ្ណោះ) ។
- សន្សំបានផ្កាយចំនួនទ្វេដង សម្រាប់ការចំណាយលើកដំបូង ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការចុះបញ្ជីគណនីក្នុងប្រព័ន្ធ ។
- សន្សំផ្កាយបន្ថែមចំនួន ៥ សម្រាប់រាល់ការទិញភេសជ្ជៈផ្តល់ជូនមានកំណត់នីមួយៗ (promotional beverage) ក្នុងសប្តាហ៍ដំបូងនៃការដាក់លក់ ។

**សមាជិកមាស៖** បន្ទាប់ពីទទួលបានផ្កាយចំនួនពីររយ (២០០) ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ លោកអ្នកនឹងត្រូវបានបញ្ចូលមកសមាជិកមាស (Gold Level) ហើយសមតុល្យនៃចំនួនផ្កាយនឹងត្រូវកំណត់សារជាថ្មី ។ ការកំណត់សារជា

ថ្មីសម្រាប់សមាជិកមាសមានន័យថា ចំនួនផ្កាយទាំងអស់នឹងត្រូវប្តូរជាចំនួនភេសជ្ជៈដោយឥតគិតថ្លៃ (គិតបង្គ្រប់ចុះ) ហើយបន្ទាប់មកវានឹងបង្ហាញតែចំនួនផ្កាយដែលនៅសល់ បន្ទាប់ពីការកំណត់សារជាថ្មីនេះតែប៉ុណ្ណោះ ។ អត្ថប្រយោជន៍សម្រាប់សមាជិកមាសមានដូចជា៖

- រាល់អត្ថប្រយោជន៍ដែលសមាជិកបៃតងទទួលបាន (ត្រូវគោរពលក្ខខណ្ឌមួយចំនួន) ។
- រង្វាន់ខួបកំណើត ។
- រង្វាន់ភេសជ្ជៈមួយកែវ ដោយឥតគិតថ្លៃ ។
- សន្សំផ្កាយបន្ថែមចំនួន ៥ សម្រាប់រាល់ការទិញភេសជ្ជៈផ្តល់ជូនមានកំណត់នីមួយៗ (promotional beverage) ក្នុងសប្តាហ៍ដំបូងនៃការដាក់លក់ ។
- សន្សំបានផ្កាយបន្ថែមចំនួន ៧ សម្រាប់រាល់ការជាវផលិតផលប្រើប្រាស់នីមួយៗ (serve-ware) ។
- ការផ្តល់ឱ្យផ្តាច់មុខ និងការផ្តល់ជូនជាពិសេស ។

៦. តើផ្កាយគឺជាអ្វី? ធ្វើយ៉ាងណាទើបសន្សំបាន?
លោកអ្នកនឹងសន្សំបានផ្កាយ និងទទួលបានអត្ថប្រយោជន៍ផ្សេងៗយ៉ាងងាយស្រួលបំផុត ដោយលោកអ្នកគ្រាន់តែធ្វើការទូទាត់ទឹកប្រាក់តាមរយៈកាត Starbucks ណាមួយដែលបានចុះបញ្ជីរួចជាស្រេចនៅក្នុងប្រព័ន្ធ នៅតាមបណ្តាហាង Starbucks ក្នុងប្រទេសកម្ពុជា ។ លោកអ្នកអាចត្រួតពិនិត្យចំនួនផ្កាយ នៅលើកម្មវិធីទូរស័ព្ទ Starbucks® Cambodia ឬចូលទៅកាន់គណនីរបស់លោកអ្នកតាមរយៈគេហទំព័រ https://card.starbucks.com.kh ។

៧. តើចំនួនផ្កាយអាចសន្សំបានដោយរបៀបណា?
លោកអ្នកនឹងទទួលបានផ្កាយចំនួនមួយ (១) សម្រាប់រាល់ការចំណាយអស់ទឹកប្រាក់ចំនួន US$0.50 ដែលការចំណាយនេះធ្វើឡើងតាមរយៈការប្រើប្រាស់កាត Starbucks តាមរយៈគណនី Starbucks របស់លោកអ្នក ឬកម្មវិធីទូរស័ព្ទ Starbucks® Cambodia នៅតាមបណ្តាហាង Starbucks ក្នុងប្រទេសកម្ពុជា ។ លោកអ្នកអាចសន្សំផ្កាយតាមរយៈការចំណាយនៅក្នុងហាងប៉ុណ្ណោះ ប៉ុន្តែមិនរាប់បញ្ចូលការបញ្ចូលទឹកប្រាក់ក្នុងកាត Starbucks ទេ ។

៨. តើខ្ញុំអាចទទួលបានផ្កាយឬទេ ប្រសិនបើខ្ញុំទូទាត់ដោយប្រើសាច់ប្រាក់សុទ្ធ ឬកាតឥណទាន/ឥណពន្ធ ជំនួសកាត Starbucks?
ដើម្បីសន្សំបានផ្កាយសម្រាប់រាល់ការជាវនៅតាមបណ្តាហាង Starbucks ក្នុងប្រទេសកម្ពុជា លោកអ្នកត្រូវទូទាត់ប្រាក់តាមរយៈកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួចហើយ ។ យើងខ្ញុំមិនអាចផ្តល់ចំនួនផ្កាយ ឬផ្តល់រង្វាន់ជូនលោកអ្នក សម្រាប់ការជាវ ដែលប្រើមធ្យោបាយទូទាត់ប្រាក់ផ្សេងពីនេះឡើយ ។ លោកអ្នកអាចប្រើសាច់ប្រាក់សុទ្ធ ឬកាតឥណទាន/ឥណពន្ធ សម្រាប់បញ្ចូលទឹកប្រាក់ចូលទៅក្នុងកាត Starbucks ។

៩. តើផ្កាយរបស់ខ្ញុំអាចផុតកំណត់ដែរឬទេ?
បន្ទាប់ពីការចុះបញ្ជីកាតក្នុងប្រព័ន្ធ លោកអ្នកមានរយៈពេល ១២ ខែ សម្រាប់សន្សំផ្កាយឱ្យបានចំនួន ២០០ ផ្កាយ ដើម្បីក្លាយជាសមាជិកមាស ។

ដើម្បីបន្តជាសមាជិកមាស លោកអ្នកត្រូវសន្សំផ្កាយឲ្យបានយ៉ាងតិច ចំនួន ២០០ ផ្កាយ ក្នុងរយៈពេល ១២ ខែ ក្រោយកាលបរិច្ឆេទគម្រប់ខួបជាសមាជិកមាស ហើយចំនួនផ្កាយសរុបរបស់លោកអ្នកនឹងត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅថ្ងៃគម្រប់ខួបនោះ (១២ ខែ ក្រោយកាលបរិច្ឆេទគម្រប់ខួបជាសមាជិកមាសកាលបរិច្ឆេទ) ។ សូមបញ្ជាក់ថា ការចាប់ផ្តើមសារជាថ្មីនៃភាពជាសមាជិកមាស មានន័យថាចំនួនផ្កាយដែលមាន នឹងត្រូវបានគណនាទៅជាចំនួនរង្វាន់ភេសជ្ជៈដោយឥតគិតថ្លៃ ហើយ ចំនួនផ្កាយដែលនៅសេសសល់ពីការគណនា នៅតែបន្តបង្ហាញ ។ ឧទាហរណ៍ ប្រសិនបើលោកអ្នកមានផ្កាយចំនួន ១៥០ ផ្កាយ ការចាប់ផ្តើមរាប់សារជាថ្មីនៃភាពជាសមាជិកមាសមានន័យថា លោកអ្នកនឹងទទួលបានភេសជ្ជៈដោយឥតគិតថ្លៃ ចំនួន ១ កែវ ហើយចំនួនផ្កាយដែល នៅសល់គឺមានចំនួន ៥០ ផ្កាយ ។ បើមិនដូច្នេះទេ លោកអ្នកនឹងក្លាយទៅជាសមាជិកបៃតងឡើងវិញ ហើយចំនួនផ្កាយរបស់លោកអ្នកនឹងត្រូវចាប់ផ្តើមសារជាថ្មីត្រឹមសូន្យ (0) ដោយស្វ័យប្រវត្តិ នៅកាលបរិច្ឆេទគម្រប់ខួបនោះ ។

ប្រសិនបើលោកអ្នកសន្សំមិនគ្រប់ចំនួន ២០០ ផ្កាយ ក្នុងរយៈពេល ១២ ខែ ដើម្បីឲ្យក្លាយជាសមាជិកមាសនោះទេ លោកអ្នកនឹងបន្តនៅជាសមាជិកបៃតង ហើយចំនួនផ្កាយរបស់លោកអ្នកនឹងត្រូវកំណត់ឲ្យស្មើសូន្យ (0) ដោយស្វ័យប្រវត្តិ នៅកាលបរិច្ឆេទគម្រប់ខួបនោះ ។

១០. តើយើងត្រូវការផ្កាយដើម្បីអ្វី?
ចំនួនផ្កាយត្រូវបានប្រើដើម្បីកំណត់សមាជិកភាព និងសម្រាប់សន្សំប្តូរយករង្វាន់ភេសជ្ជៈដោយឥតគិតថ្លៃជាដើម ។ តារាងខាងក្រោមជាព័ត៌មានទាក់ទងនឹងសមាជិកភាព ។

| **ចំនួនផ្កាយ** | **សមាជិកភាព** |
|---|---|
| 0 - 199 | សមាជិកបៃតង |
| 200 - 200+ | សមាជិកមាស |

១១. តើខ្ញុំចាំបាច់ត្រូវតែយកកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួច ដើម្បីទទួលបានផ្កាយ?
បច្ចុប្បន្ននេះ លោកអ្នកត្រូវទូទាត់ប្រាក់លើការជាវរបស់លោកអ្នក តាមរយៈកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួចហើយ ទើបយើងខ្ញុំអាចបញ្ចូលចំនួនផ្កាយជូនលោកអ្នកបាន ។ ប្រសិនបើលោកអ្នកបានទាញយក (download) កម្មវិធីទូរស័ព្ទ Starbucks® Cambodia ចូលទៅក្នុងទូរស័ព្ទរបស់លោកអ្នក ហើយនិងបានប្រើប្រាស់អាសយដ្ឋានអ៊ីម៉ែល តែមួយជាមួយនឹងអាសយដ្ឋានអ៊ីម៉ែល ដែលលោកអ្នកបានប្រើសម្រាប់ចុះបញ្ជីគណនីរបស់លោកអ្នក លោកអ្នកក៏អាចធ្វើការទូទាត់ប្រាក់តាមរយៈការបង្ហាញបារកូដនៅលើកម្មវិធី Starbucks® Cambodia ទៅកាន់បុគ្គលិកក្នុងហាង Starbucks នៅក្នុងប្រទេសកម្ពុជា ។ សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័រ https://card.starbucks.com.kh ។

១២. តើរយៈពេលប៉ុន្មានទើបខ្ញុំអាចមើលឃើញចំនួនផ្កាយដែលទទួលបាន បន្ទាប់ពីខ្ញុំប្រើកាត Starbucks ដែលបានចុះបញ្ជីរួច?
ចំនួនផ្កាយដែលទទួលបានពីការប្រើប្រាស់កាត Starbucks ដែលបានចុះបញ្ជី របស់លោកអ្នក នឹងត្រូវបង្ហាញឲ្យឃើញនៅក្នុងគណនីរបស់លោកអ្នក ក្នុងរយៈពេលដែលលឿនបំផុត គឺ ៤៨ ម៉ោង បន្ទាប់ពីបញ្ចប់ប្រតិបត្តិការបង់ប្រាក់ ។

១៣. តើខ្ញុំអាចប្តូរយករង្វាន់ដោយរបៀបណា?
គ្រាន់តែធ្វើការជូនដំណឹងដល់បុគ្គលិកធ្វើការក្នុងហាង Starbucks នៅក្នុងប្រទេសកម្ពុជា ពីការប្តូរយករង្វាន់ ។ លោកអ្នកអាចស្កេនបារកូដនៅលើកម្មវិធីទូរស័ព្ទ Starbucks® Cambodia ឬគ្រាន់តែប្រើកាត Starbucks ណាមួយដែលបានចុះបញ្ជីរួច ដើម្បីប្តូរយករង្វាន់ ។ លើសពីនេះទៀត លោកអ្នកត្រូវទូទាត់ប្រាក់លើការចំណាយទាំងអស់ដោយប្រើកាត Starbucks ដែលចុះបញ្ជីរួច (លើកលែងតែការប្តូរយករង្វាន់ឥតគិតថ្លៃប៉ុណ្ណោះ) ដើម្បីសន្សំ ឬប្តូរយករង្វាន់ ។

សូមបញ្ជាក់៖ រង្វាន់ឬការផ្តល់ជូននីមួយៗមានកាលបរិច្ឆេទផុតកំណត់ផ្សេងៗគ្នា ។ ចំនួនផ្កាយដែលអាចប្តូរយករង្វាន់បាននឹងត្រូវផុតកំណត់នៅថ្ងៃគម្រប់ខួប រីឯការផ្តល់ជូនដ៏ទៃទៀតនៅក្នុងគណនី Starbucks របស់លោកអ្នកនឹងត្រូវផុតកំណត់ទៅតាមលក្ខខណ្ឌនៃការផ្តល់ជូននោះ ។ លោកអ្នកអាចពិនិត្យមើលរង្វាន់និងការផ្តល់ជូនផ្សេងៗរបស់លោកអ្នក តាមរយៈគេហទំព័រ https://card.starbucks.com.kh ឬតាមរយៈកម្មវិធីទូរស័ព្ទ Starbucks® Cambodia ។ សូមប្តូររង្វាន់របស់លោកអ្នក ឲ្យបានមុនថ្ងៃផុតកំណត់ ។

១៤. តើមានការកំណត់ពេលវេលាទៅលើការសន្សំផ្កាយដើម្បីឈានទៅកាន់សមាជិកភាពបន្ទាប់ដែរឬទេ?
ចំនួនផ្កាយដែលសន្សំបាននឹងត្រូវគណនាជាប្រចាំឆ្នាំ ទៅតាមកាលបរិច្ឆេទគម្រប់ខួបនៃសមាជិកភាពរបស់លោកអ្នក (កាលបរិច្ឆេទដែលលោកអ្នកទទួលបាន សមាជិកភាពបច្ចុប្បន្ន) ដើម្បីកំណត់កម្រិតនៃសមាជិកភាពរបស់លោកអ្នក ។ ការបូកសរុបនៃចំនួនផ្កាយដែលសន្សំបាននឹងត្រូវបានគណនាជារៀងរាល់ឆ្នាំ ។

១៥. តើខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីបន្តនៅជាសមាជិកមាស?
លោកអ្នកនឹងនៅជាសមាជិកមាសពេញមួយឆ្នាំ គិតចាប់ពីថ្ងៃដែលលោកអ្នកក្លាយជាសមាជិកមាស ហើយថ្ងៃនោះនឹងក្លាយជាកាលបរិច្ឆេទគម្រប់ខួបថ្មីរបស់លោកអ្នក ។ គ្រាន់តែសន្សំឲ្យបាន ២០០ ផ្កាយបន្ថែមទៀត មុនពេលកាលបរិច្ឆេទគម្រប់ខួបមកដល់ (កាលបរិច្ឆេទដែលអ្នកបានក្លាយជាសមាជិកមាស) លោកអ្នកនឹងបន្តរីករាយជាមួយអត្ថប្រយោជន៍របស់សមាជិកមាស រយៈពេលមួយឆ្នាំបន្តទៀត ។

១៦. តើត្រូវបង់ប្រាក់ឬទេ ក្នុងការចូលរួមកម្មវិធី Starbucks Rewards™ ?
មិនមានការបង់ប្រាក់អ្វីទេក្នុងការចូលរួមកម្មវិធី Starbucks Rewards™ ប៉ុន្តែលោកអ្នកត្រូវការកាត Starbucks ដែលមានទឹកប្រាក់យ៉ាងតិចបំផុតចំនួន ប្រាំ (៥) ដុល្លារអាមេរិក ដើម្បីចុះឈ្មោះចូលក្នុងគណនី Starbucks Rewards™ ។

១៧. តើខ្ញុំអាចមើលប្រវត្តិប្រតិបត្តិការរបស់ខ្ញុំបានទេ?
លោកអ្នកអាចចូលមើល ប្រវត្តិប្រតិបត្តិការរបស់លោកអ្នកបាន តាមរយៈគេហទំព័រ https://card.starbucks.com.kh ឬទាញយកកម្មវិធី Starbucks® Cambodia ហើយចូលទៅកាន់ប្រវត្តិប្រតិបត្តិការគណនីរបស់លោកអ្នក (Account Transaction History) ។

១៨. តើខ្ញុំអាចមើលតារាងរង្វាន់របស់ខ្ញុំបានទេ?
លោកអ្នកអាចចូលទៅមើល តារាងរង្វាន់របស់លោកអ្នកបាន តាមរយៈគេហទំព័រ https://card.starbucks.com.kh ឬទាញយកកម្មវិធី Starbucks® Cambodia ដើម្បីមើលតារាងរង្វាន់របស់លោកអ្នក ។

១៩. តើខ្ញុំអាចមើលទឹកប្រាក់កាត Starbucks របស់ខ្ញុំបានដោយរបៀបណា?
លោកអ្នកអាចចូលទៅកាន់គណនីរបស់លោកអ្នក ដើម្បីមើលទឹកប្រាក់នៅសល់ តាមរយៈគេហទំព័រ https://card.starbucks.com.kh ។ ជម្រើសមួយទៀតគឺ លោកអ្នកក៏អាចទាញយកកម្មវិធីទូរស័ព្ទ Starbucks® Cambodia ដើម្បីមើលទឹកប្រាក់នៅសល់ក្នុងកាតរបស់លោកអ្នកបានដែរ ឬអាចសាកសួរបុគ្គលិករបស់ហាងយើងខ្ញុំនៅតាមបណ្តាហាង Starbucks ក្នុងប្រទេសកម្ពុជា ។

២០.បន្ទាប់ពីខ្ញុំបានទទួលវិក្កយបត្ររួច តើខ្ញុំអាចឆែកមើលប្រវត្តិប្រតិបត្តិការនៅក្នុងកម្មវិធី Starbucks® Cambodia បានដែរឬទេ?
ប្រាកដណាស់ លោកអ្នកអាចឆែកមើលរាល់ប្រតិបត្តិការនៃកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួច តាមរយៈកម្មវិធីទូរស័ព្ទ Starbucks® Cambodia (Account Transaction History) ឬគេហទំព័រនៅក្នុងផ្នែកប្រវត្តិប្រតិបត្តិការ ។ ព័ត៌មានលម្អិត គឺដូចគ្នានឹងវិក្កយបត្រដែលលោកអ្នកទទួលបាន ។

២១. តើធ្វើដូចម្តេចប្រសិនបើចំនួនផ្កាយរបស់ខ្ញុំមិនត្រឹមត្រូវ? តើខ្ញុំត្រូវទាក់ទងនរណា?
យើងខ្ញុំចង់ធានាឲ្យបានថាសមតុល្យសាច់ប្រាក់នៅក្នុងគណនីរបស់លោកអ្នក ត្រឹមត្រូវទៅតាមការជាវរបស់លោកអ្នកប្រាកដមែន ។ ប្រសិនបើចំនួនផ្កាយសរុបមានភាពមិនត្រឹមត្រូវ សូមទាក់ទងមកកាន់ផ្នែកបម្រើសេវាអតិថិជនរបស់យើងខ្ញុំតាមទូរស័ព្ទលេខ ០២៣ ៩៨៦ ៥៩១។

លោកអ្នកត្រូវមានលេខកូដកាត 16 ខ្ទង់ក្នុងដៃ នៅពេលទាក់ទងមក ដើម្បីងាយស្រួលក្នុងការបញ្ជាក់អត្តសញ្ញាណ ។ សូមបញ្ជាក់ថា ចំនួនផ្កាយនិងប្រវត្តិប្រតិបត្តិការទាំងអស់ នឹងធ្វើបច្ចុប្បន្នភាពរៀងរាល់ ៤៨ ម៉ោងម្តង ។

២២. ហេតុអ្វីខ្ញុំចាំបាច់ត្រូវចុះបញ្ជីគណនីរបស់ខ្ញុំនៅក្នុងប្រព័ន្ធ ដើម្បីចូលរួមក្នុងកម្មវិធី Starbucks Rewards™ ?
ការចុះបញ្ជីកាត Starbucks របស់លោកអ្នកនៅក្នុងប្រព័ន្ធ គឺជាវិធីតែមួយគត់ ដើម្បីចូលរួមកម្មវិធី Starbucks Rewards™ ។ ការបង្កើតគណនីនេះជាជំហានចាំបាច់ក្នុងការចុះឈ្មោះរបស់លោកអ្នក ដើម្បីទទួលបានរង្វាន់និងការផ្តល់ជូនពិសេសៗ ដែលមានសម្រាប់តែសមាជិក Starbucks Rewards™ ប៉ុណ្ណោះ ។ លើសពីនេះ តាមរយៈការចុះបញ្ជីកាត Starbucks របស់លោកអ្នកនៅក្នុងប្រព័ន្ធ លោកអ្នកនឹងទទួលបានការការពារសមតុល្យផ្កាយ ក្នុងករណីដែលកាតរបស់លោកអ្នកត្រូវបាត់បង់ លួច ឬខូចខាត ។ ម៉្យាងវិញទៀត ជាមួយនឹងកាត Starbucks ដែលបានចុះ

បញ្ចីរួច លោកអ្នកក៏អាចគ្រប់គ្រងគណនី និងកាតផ្សេងៗទៀត តាមវិធីសាស្ត្រច្រើនយ៉ាង ដូចជាការបង់ប្រាក់តាមកម្មវិធីទូរស័ព្ទ Starbucks® Cambodia ជាដើម ។

សូមបញ្ជាក់ថាលោកអ្នកត្រូវមានអ៊ីម៉ែល អាសយដ្ឋាន ថ្ងៃខែកំណើត និងលេខទូរស័ព្ទដៃដែលត្រឹមត្រូវ សម្រាប់ការបង្កើតគណនីចុះឈ្មោះកាត ។

២៣. តើកាតអាចប្តូរជាសាច់ប្រាក់បានវិញឬទេ?
រាល់សមតុល្យទឹកប្រាក់ក្នុងកាត Starbucks មិនអាចប្តូរជាសាច់ប្រាក់វិញបានទេ ។

២៤. តើចំនួនផ្កាយដែលមានក្នុងគណនីរបស់ខ្ញុំអាចផ្ទេរទៅឲ្យអ្នកដ៏ទៃបានឬទេ?
សូមអភ័យទោស ចំនួនផ្កាយដែលសន្សំបានក្នុងគណនីនីមួយៗ អាចប្រើបានដោយម្ចាស់គណនីនោះតែប៉ុណ្ណោះ ហើយមិនអាចផ្ទេរទៅកាន់គណនីផ្សេងបានទេ ។

២៥. តើខ្ញុំអាចផ្ទេរសមាជិកភាព Starbucks Rewards™ ទៅឲ្យអ្នកដ៏ទៃបានឬទេ?

សូមអភ័យទោស សមាជិកភាពទាំងអស់មិនអាចធ្វើការផ្ទេរបានទេ ហើយក៏មិនអាចចែករំលែកជាមួយសមាជិកគ្រួសារ មិត្តភក្តិ ឬអ្នកដ៏ទៃទៀតដែរ ។

២៦. តើ Starbucks អាចការពារសិទ្ធិឯកជនរបស់ខ្ញុំដោយរបៀបណា បន្ទាប់ពីខ្ញុំចុះឈ្មោះកាត Starbucks រួច?
សូមអានគោលការណ៍សិទ្ធិឯកជនរបស់យើងខ្ញុំ សម្រាប់ព័ត៌មានលម្អិត ។

២៧. តើទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំអាចនឹងផ្តល់ឲ្យក្រុមហ៊ុនដ៏ទៃដែរឬទេ?
រាល់ព័ត៌មានដែលលោកអ្នកផ្តល់ឲ្យ នឹងត្រូវបានប្រើប្រាស់សម្រាប់ការរក្សាទំនាក់ទំនងរវាងយើងខ្ញុំជាមួយលោកអ្នកតែប៉ុណ្ណោះ យើងអាចនឹងចែករំលែកព័ត៌មានទាំងនោះ សម្រាប់តែគោលបំណងដែលបានចែងក្នុងគោលការណ៍សិទ្ធិឯកជនរបស់យើងខ្ញុំ ។ សូមអានគោលការណ៍ការសិទ្ធិឯកជនរបស់យើងខ្ញុំ សម្រាប់ព័ត៌មានលម្អិត ។

២៨. តើរាល់កាត Starbucks ទាំងអស់មានសិទ្ធិទទួលបានអត្ថប្រយោជន៍ពី Starbucks Rewards™ មែនទេ?
រាល់កាត Starbucks ដែលបានចុះឈ្មោះរួច គឺអាចមានសិទ្ធិទាំងអស់ ។ កាតដែលបានទិញ ឬចុះឈ្មោះនៅក្រៅប្រទេសកម្ពុជា នឹងមិនត្រូវបានទទួលស្គាល់ ហើយមិនអាចទទួលបានការសន្សំផ្កាយ ឬអត្ថប្រយោជន៍ពីកម្មវិធី Starbucks Rewards™ នោះទេ ។

២៩. ហេតុអ្វីបានជាខ្ញុំមិនអាចធ្វើបច្ចុប្បន្នភាពចុងក្រោយលើកម្មវិធីទូរស័ព្ទ Starbucks® Cambodia នៅលើទូរស័ព្ទដៃរបស់ខ្ញុំបាន?
ប្រសិនបើលោកអ្នកមានកម្មវិធីទូរស័ព្ទ Starbucks® Cambodia (ប្រព័ន្ធ iOS/Android) ស្រាប់ ហើយលោកអ្នកមិនអាចធ្វើបច្ចុប្បន្នភាពចុងក្រោយទៅលើកម្មវិធីនោះបានដោយស្វ័យប្រវត្តិ លោកអ្នកគ្រាន់តែលុបកម្មវិធីនោះចោល ហើយទាញយកកម្មវិធីថ្មីពី App Store ឬ Google Play Store ។